ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ
លេខ:.................អសជ/.....

# របាយការណ៍សវនកម្មលើកិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងបំភ្លឺសាធារណៈ នៅខេត្តកំពង់ឆ្នាំង

ការិយបរិច្ឆេទ ២០២២

## សេចក្តីសង្ខេប

រដ្ឋបាលខេត្តកំពង់ឆ្នាំង បានរៀបចំបង្កើតឱ្យមានប្រព័ន្ធភ្លើងបំភ្លឺសាធារណៈនៅតាមបណ្តាសួនច្បារ និងផ្លូវសាធារណៈជាច្រើនទីតាំងក្នុងដែនដីខេត្ត ដោយផ្សារភ្ជាប់ទៅនឹងគោលបំណងរាជរដ្ឋាភិបាលដែលផ្តោតការយកចិត្តទុកដាក់លើការប្រកួតប្រជែងទីក្រុងស្អាត បដិសណ្ឋារកិច្ចល្អ ម្ចាស់ផ្ទះកម្ពុជា ផ្តល់នៅភាពកក់ក្តៅ និងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ម្យ៉ាងវិញទៀត ខេត្តមានបំណងតម្រង់ទិសការគ្រប់គ្រងបំភ្លឺសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាពលើការគ្រប់គ្រង និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធភ្លើងបំភ្លឺសាធារណៈនៅតាមដងផ្លូវ ស្ពាន អគារសាធារណៈ តំបន់បេតិកភណ្ឌ និងតាមសួនច្បារសាធារណៈ ព្រមទាំងប្រព័ន្ធភ្លើងស្តុបចរាចរ ប្រព័ន្ធភ្លើងប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្ម និងប្រព័ន្ធភ្លើងតាំងលម្អ ពិធីបុណ្យជាតិ និងអន្តរជាតិនៅក្នុងដែនដីគ្រប់គ្រងរដ្ឋបាលរបស់ខ្លួន ទន្ទឹមនឹងនេះខេត្តក៏បានចំណាយលើការបំភ្លឺសាធារណៈទៅតាមទំហំថវិកា និងតម្រូវការរបស់ប្រជាជននៅក្នុងខេត្ត ដើម្បីបំភ្លឺតាមដងផ្លូវឱ្យមានសុវត្ថិភាពផងដែរ។

ដោយសារតែតម្រូវនៃការប្រើប្រាស់បង្គោលភ្លើងនៅតាមសួនច្បារសាធារណៈ និងផ្លូវថ្នល់មានការកើនឡើងច្រើននៅចំនួនបង្គោលភ្លើង និងអំពូល ជាហេតុនាំឱ្យរដ្ឋបាលខេត្តមានការចំណាយថវិកាច្រើន និងពុំមានថវិកាគ្រប់គ្រាន់សម្រាប់ការថែទាំ និងជួសជុល ដូច្នេះហើយ នៅឆ្នាំ២០២០ មានក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិចស៊ីធី បានចុះមកសិក្សា និងធ្វើបទបង្ហាញអំពីការផ្លាស់ប្តូរអំពូលភ្លើងដែលមានកម្លាំង ២៥០ វ៉ាត់ មកប្រើប្រាស់អំពូលឆ្លាតវៃ ដែលមានកម្លាំង ១០០ វ៉ាត់ វិញ។ ក្រោយពីបានស្តាប់អំពីការធ្វើបទបង្ហាញឃើញនៅកម្រិតសន្សំសំចៃថវិកា និងមានប្រសិទ្ធភាពផងនោះ រដ្ឋបាលខេត្តបានសម្រេចចុះកិច្ចសន្យាជាមួយក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិចស៊ីធី នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដោយផ្តល់សិទ្ធិលើការវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈក្នុងខេត្តកំពង់ឆ្នាំង ដែលមានរយៈពេល១៥ ឆ្នាំ ដោយត្រូវធ្វើការផ្លាស់ប្តូរអំពូលឱ្យបានសរុបចំនួន ១ ៤១១ អំពូលក្នុងខេត្ត។ ប៉ុន្តែគិតរហូតមកដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ នេះ ក្រុមហ៊ុន វីសាន់ បានផ្លាស់ប្តូរ និងតម្លើងអំពូលសរុបចំនួន ១ ២៨៩ អំពូល នៅខ្វះ១២២ អំពូលដែលមិនទាន់មានទីតាំងត្រូវបំពាក់អំពូល។

គោលបំណងនៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការនៃការគ្រប់គ្រងបំភ្លឺសាធារណៈ ផ្តោតសំខាន់លើ ៖

- ប្រសិទ្ធភាពនៃការសន្សំសំចៃ ក្នុងការបំភ្លឺសាធារណៈ
- ការអនុវត្តសមស្របតាមកម្មវិធីវិនិយោគ០៣ ឆ្នាំរំកិលដែរឬទេ?
- ការអនុវត្តកិច្ចសន្យារវាងក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិច ស៊ីធី ជាមួយរដ្ឋបាលខេត្ត

តាមរយៈនៃការចុះធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងបំភ្លឺសាធារណៈនៅរដ្ឋបាលខេត្តកំពង់ឆ្នាំងសម្រាប់ការិយបរិច្ឆេទ២០២២ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តកំពង់ឆ្នាំងអនុវត្តមិនទាន់បានល្អប្រសើរចំពោះកិច្ចសន្យាស្តីពីការផ្តល់សិទ្ធិវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងសាធារណៈ រវាងរដ្ឋបាលខត្តកំពង់ឆ្នាំង និងក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិចស៊ីធី។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តកំពង់ឆ្នាំង គួរតែពិនិត្យឡើងវិញ និងកែសម្រួលចំណុចមួយចំនួនក្នុងកិច្ចសន្យា សំដៅពង្រឹងដល់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចសន្យា ដើម្បីធានាបាននូវភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផល ដែលបានមកពីការវិនិយោគ។

អាជ្ញាធរសវនកម្មជាតិ សូមបង្ហាញជូននូវលទ្ធផលសំខាន់ៗមួយចំនួននៃការធ្វើសវនកម្ម ដូចខាងក្រោម៖

**១. ការវិនិយោគរបស់ក្រុមហ៊ុនជាមួយរដ្ឋបាលខេត្តមិនបានផ្តល់ភាពសន្សំសំចៃ**

កិច្ចសន្យាស្តីពីការផ្តល់សិទ្ធិវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈក្នុងខេត្តកំពង់ឆ្នាំងជាមួយក្រុមហ៊ុន វីសាន់ ឌីវេឡុបម៉ិន អេឡិចទ្រីស៊ីធី ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បានកំណត់ពី ទំហំថវិកា១០% នៃទំហំថវិកាសន្សំសំចៃថាមពលដែលនៅសល់បន្ទាប់ពីរដ្ឋបាលខេត្តកំពង់ឆ្នាំងបានធ្វើការទូទាត់ជូនក្រុមហ៊ុន វីសាន់ ឌីវេឡុបម៉ិន អេឡិកទ្រីស៊ីធីប្រចាំខែ ត្រូវរក្សាទុកក្នុងគណនីរបស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ដើម្បីប្រើប្រាស់លើការងារហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងធ្វើការទូទាត់ជូនក្រុមហ៊ុន វីសាន់ ដែលជាអ្នកជួសជុលហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ តាមការចុះសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងបំភ្លឺសាធារណៈនៅរដ្ឋបាលខេត្តកំពង់ឆ្នាំង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈក្នុងខេត្តកំពង់ឆ្នាំង ដោយធ្វើការផ្លាស់ប្តូរអំពូលឆ្លាតវៃពីកម្លាំង ២៥០ វ៉ាត់ មកប្រើអំពូលឆ្លាតវៃ ១០០ វ៉ាត់ ដោយរក្សាបាននៅភាពសន្សំសំចៃ ១៥០ វ៉ាត់ ដោយធ្វើការទូទាត់ថ្លៃភ្លើងបំភ្លឺសាធារណៈ ដែលបានពីការសន្សំសំចៃនេះ ហើយរដ្ឋបាលខេត្តបានទទួល១០% ពីការសន្សំសំចៃនេះ សម្រាប់រក្សាទុកក្នុងគណនីរបស់រដ្ឋបាលខេត្ត ដើម្បីប្រើប្រាស់លើការងារហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប៉ុន្តែរដ្ឋបាលខេត្តមិនបានទទួលផលប្រយោជន៍ពីការសន្សំសំចៃ១០% នេះឡើយ ។[១]

**២. ការមិនបានតាមដានការអនុវត្តផ្លាស់ប្តូរអំពូលវៃឆ្លាត**

កិច្ចសន្យាស្តីពីការផ្តល់សិទ្ធិវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈក្នុងខេត្តកំពង់ឆ្នាំងជាមួយក្រុមហ៊ុន វីសាន់ ឌីវេឡុបម៉ិន អេឡិចទ្រីស៊ីធី ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ត្រង់ឧបសម្ព័ន្ធ(១) នៃកិច្ចសន្យាតារាងចំនួនបង្គោល និងចំនួនអំពូលតាមដងផ្លូវនីមួយៗក្នុងក្រុងកំពង់ឆ្នាំង ...អំពូលសូត្យូមតុងស្បូងខ្ពស់HPS(250W)មានចំនួន៧១៩ និងអំពូល LED(100W)មានចំនួន២៤៧ សរុបមានចំនួន៩៦៦អំពូល និងត្រង់ឧបសម្ព័ន្ធ២ នៃកិច្ចសន្យាត្រង់ចំណុចទី២ បញ្ជីរាយនាមទ្រព្យសម្បត្តិ និងវត្ថុផ្សេងៗដែលត្រូវផ្ទេរ ។

---

[១] កិច្ចសន្យាស្តីពីការផ្តល់សិទ្ធិវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ត្រង់ប្រការ៨ និងប្រការ១១

| ល.រ | ឈ្មោះផលិតផល | តាមកិច្ចសន្យា | រាប់ជាក់ស្តែង | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន(កំផ្លេ) | ចំនួន(កំផ្លេ) | |
| ១ | អំពូលបំភ្លឺតាមដងផ្លូវប្រភេទអុិលអុីឌី(100W) | ១ ៨១១ | ១ ២២១ | ជាក់ស្តែងអំពូលមាន ២ ប្រភេទ LED ធម្មតា និង LED វៃឆ្លាត |
| ២ | ឧបករណ៍គ្រប់គ្រងអំពូល | ១ ៨១១ | ១ ២២១ | |
| ៣ | ឧបករណ៍ក្នុងទូភ្លើង(រួមមានកុងទ័រឆ្លាតវៃ និងឧបករណ៍បញ្ជូនចរន្ត) | ៨២ | ៨៤ | |
| ៤ | ប្រព័ន្ធគ្រប់គ្រងឆ្លាតវៃ(កម្មវិធីគ្រប់គ្រងស៊ើវើ ស្ថានីយ៍ការងារ ផ្ទាំងបង្ហាញរូបភាព) | ១ | ០ | |

ការបង្ហាញនេះបញ្ជាក់ឱ្យឃើញថាការអនុវត្តកិច្ចសន្យា ការផ្ទេរអំពូលបំភ្លឺប្រភេទអុិលអុីឌី(100W)តាមដងផ្លូវមិនបានប្តូរអំពូលប្រភេទLED(100W) ដែលមានស្រាប់ចំនួន២៨៧អំពូលនោះឡើយ ឧបករណ៍គ្រប់គ្រងអំពូលក៏មិនបានប្តូរទាំងអស់ដែរ និងប្រព័ន្ធគ្រប់គ្រងឆ្លាតវៃ(កម្មវិធីគ្រប់គ្រងស៊ើវើ ស្ថានីយ៍ការងារ ផ្ទាំងបង្ហាញរូបភាព)ក៏មិនបានតំឡើងដែរ។

### ៣. កង្វះខាតក្នុងការលើកគម្រោងស្ថាបនាសាងសង់បង្គោលភ្លើងសាធារណៈក្នុងផែនការយុទ្ធសាស្ត្រថវិកាខេត្ត

យោងតាមកិច្ចសន្យាវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈក្នុងខេត្តកំពង់ឆ្នាំង ក្រុមហ៊ុនត្រូវបំពាក់អំពូលឆ្លាតវៃសរុប១៨១១ អំពូល ប៉ុន្តែក្រុមហ៊ុនបានធ្វើការផ្លាស់ប្តូរអំពូលឆ្លាតវៃបានសរុបចំនួន ១២៨៩ អំពូល ដែលនៅខ្វះអំពូលចំនួន១២២ ទៀត ដែលត្រូវបំពាក់។ ប៉ុន្តែជាក់ស្តែងគិតរហូតមកដល់ដំណាច់ឆ្នាំ២០២២ រដ្ឋបាលខេត្តនៅមិនទាន់បានរៀបចំគម្រោងស្ថាបនាសាងសង់បង្គោលភ្លើងបំភ្លឺសាធារណៈឡើយដោយសារការិយបរិច្ឆេទ២០២២-២០២៤ រដ្ឋបាលខេត្តមិនបានរៀបចំផែនការយុទ្ធសាស្ត្រថវិកានៅឡើយ។

### ៤. កង្វះខាតក្នុងការបង្កើតក្រុមការងារតាមដាន ជួសជុល និងគ្រប់គ្រងបង្គោលភ្លើងសាធារណៈ

ចំពោះការងារជួសជុល និងថែទាំលើការគ្រប់គ្រងបំភ្លឺសាធារណៈ ក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិច ស៊ីធី គឺជាអ្នកទទួលក្នុងការជួសជុល និងថែទាំ ដែលបណ្តាលមកពីភាពរអាក់រអួលនៃការផ្គត់ផ្គង់អគ្គិសនី ការបាត់បង់ខ្សែកាប្លិ៍ បញ្ហាបង្គោលភ្លើង ឬបញ្ហាខ្សែកាប្លិ៍ បញ្ហាអំពូលហ្វាបញ្ហាអំពូលភ្លើងបំភ្លឺតាមសួនច្បារ និងបញ្ហាអំពូលភ្លើងបំភ្លឺនៅរង្វង់មូល។ល។ ហើយបន្ទុកលើការចំណាយលើការថែទាំ និងជួសជុលនៃវិស្វកម្មប្រភេទនេះ រដ្ឋបាលនឹងធ្វើការទូទាត់ជូនក្រុមហ៊ុនវីសាន់ ទៅតាមភាពជាក់ស្តែងដែលក្រុមហ៊ុន វីសាន់ បានដាក់ស្នើជាមុន បន្ទាប់ពីរដ្ឋបាលខេត្តបានពិនិត្យបញ្ជាក់លើការជួសជុលរួចរាល់។ ម្យ៉ាងវិញទៀត ចំពោះការចំណាយក្នុងការថែទាំ និងជួសជុល

អំពូលភ្លើងតាមដងផ្លូវ និងប្រព័ន្ធគ្រប់គ្រងភ្លើងបំភ្លឺឆ្លាតវៃដែលតម្លើងដោយ ក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិចស៊ីធី គឺជាបន្ទុករបស់ក្រុមហ៊ុន។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការថែទាំក្នុងការជួសជុលបង្គោលភ្លើងសាធារណៈ នាពេលកន្លងមក គឺក្រុមហ៊ុនបានជួសជុល និងទូទាត់ចំណាយជាមួយរដ្ឋបាលខេត្ត ដោយប្រើប្រាស់កញ្ចប់ថវិកា១០% ដែលបានមកពីការសន្សំសំចៃ ប៉ុន្តែតាមការចុះពិនិត្យជាក់ស្តែងឃើញថា បង្គោលភ្លើងសាធារណៈក្នុងខេត្តមានសរុបចំនួន ១២២១ អំពូល ក្នុងនោះ អំពូលមិនភ្លឺមានចំនួន២៣ អំពូល និងអំពូលខ្សោយពន្លឺមានចំនួន ៦២ អំពូល មិនតែប៉ុណ្ណោះ ខ្សែភ្លើងដែលត្រូវបង្កប់ក្នុងដី គឺមិនបានរៀបចំឱ្យត្រឹមត្រូវឡើយ កន្លែងខ្លះខ្សែភ្លើងរត់នៅលើដី ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ជាយថាហេតុ។ ករណីនេះ ដោយសារតែរដ្ឋបាលខេត្តមិនមានក្រុមការងារតាមដាន គ្រប់គ្រងលើការជួសជុលបង្គោលភ្លើងបំភ្លឺសាធារណៈឱ្យបានត្រឹមត្រូវ ដោយមានតែមន្ត្រីជាប់កិច្ចសន្យាម្នាក់ជាអ្នកមើល ដោយមិនបានធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវបង្ហាញពីការមានបញ្ហាបង្គោលភ្លើងដែលដាច់ខ្សែ ឬក៏អំពូល ដែលមិនភ្លឺឡើយ ហើយចំពោះអំពូលភ្លើងដែលក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រិចស៊ីធី បានបំពាក់ជាបន្ទុករបស់ក្រុមហ៊ុនដែលត្រូវធ្វើការផ្លាស់ប្តូរថែទាំជាប្រចាំផងដែរ។[២]

### ៥. ការទូទាត់ជូនក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន មិនសមស្របតាមកិច្ចសន្យា

រដ្ឋបាលខេត្តជាអ្នកទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី ទៅឱ្យក្រុមហ៊ុនសេវាករអគ្គិសនីដោយផ្ទាល់ដោយផ្អែកលើវិក្កយបត្រដែលចេញដោយក្រុមហ៊ុនសេវាករអគ្គិសនី។ ដោយឡែករដ្ឋបាលខេត្តត្រូវទូទាត់ថ្លៃចំណាយលើការវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈទៅតាមរូបមន្តគណនា ដូចមានចែងក្នុងប្រការ៧(ប្រាំពីរ) ចំណុច៧.២ និងចំណុច៧.៣ នៃកិច្ចសន្យា ទៅឱ្យក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រីស៊ីធី ជារៀងរាល់ខែជាសាច់ប្រាក់ ឬបង្វែរចូលគណនីធនាគាររបស់ក្រុមហ៊ុន។ ចំពោះទំហំថវិកាសន្សំសំចៃថាមពលគឺត្រូវយកទំហំចំណាយលើថាមពលអគ្គិសនីប្រចាំខែនៃភ្លើងបំភ្លឺសាធារណៈដែលមានចែងក្នុងប្រការ៦ (ប្រាំមួយ) នៃកិច្ចសន្យាដកនឹងទំហំចំណាយលើការប្រើប្រាស់ថាមពលប្រចាំខែដោយផ្អែកលើវិក្កយបត្រចេញដោយក្រុមហ៊ុនសេវាករអគ្គិសនី។

រដ្ឋបាលខេត្តបានធ្វើការទូទាត់ថ្លៃអគ្គិសនីជូនក្រុមហ៊ុន វីសាន់ ឌីវេឡុបមិន អេឡិចទ្រីស៊ីធី ជារៀងរាល់ខែ ដោយគិតតាមរូបមន្ត (បរិមាណចំនួនអំពូលសរុប x អានុភាពនៃកម្លាំងអំពូល (0,15w) x12 ម៉ោង x31 ថ្ងៃ)។ ករណីនេះ ដោយសារតែរដ្ឋបាលខេត្តពិបាកក្នុងការកំណត់បែងចែកកុងទ័រភ្លើងជាពីរព្រោះក្រុមហ៊ុនសេវាករអគ្គិសនីមិនព្រមក្នុងការបំបែកកុងទ័រផ្សេងសម្រាប់ការបំភ្លឺសាធារណៈ ដូច្នេះត្រូវបូកសរុបជាមួយការប្រើក្នុងរដ្ឋបាលខេត្ត ហេតុនេះរដ្ឋបាលខេត្តសម្រេចឱ្យក្រុមហ៊ុន វីសាន់ គិតតាមរូបមន្តដូចខាងលើតែម្តង។ ករណីនេះទូទាត់បែបនេះ មិនបានបង្ហាញពីការ

---

[២] កិច្ចសន្យាស្តីពីការផ្តល់សិទ្ធិវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ត្រង់ប្រការ១១ ចំណុច១១.៥

សន្សំសំចៃឡើយ និងតាមការពិនិត្យជាក់ស្តែង រដ្ឋបាលខេត្តបានបែងចែកប្រអប់ភ្លើងសម្រាប់បំភ្លឺសាធារណៈ និងប្រអប់ភ្លើងសម្រាប់ប្រើប្រាស់រដ្ឋបាលខេត្តដែលប្រអប់ភ្លើងបំភ្លឺសាធារណៈមានសរុបចំនួន ៥៤ ប្រអប់។[៣]

**៦. កង្វះខាតវិធានការក្នុងការពិនិត្យឯកសារស្នើសុំទូទាត់**

រដ្ឋបាលខេត្តបានទូទាត់ថ្លៃអគ្គិសនីជូនក្រុមហ៊ុន វីសាន់ ដោយផ្អែកតាមឯកសារស្នើសុំរបស់ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនបានកំណត់យកបរិមាណអំពូលសរុបជាប្រចាំខែ ១ ២៨៩ អំពូល មកធ្វើការគណនាតាមរូបមន្ត ហើយគិតថវិកាតែម្តង។ ករណីនេះ រដ្ឋបាលខេត្តមិនមានឯកសាររបាយការណ៍ណាបញ្ជាក់អំពីការតាមដានក្នុងការប្រើប្រាស់ប្រចាំខែនៅចំនួនអំពូលដែលមិនភ្លឺ ឬក៏បណ្តាលមកពីបញ្ហាខ្សែភ្លើងដាច់ផ្សេងៗ ដែលជាហេតុនាំឱ្យអំពូលមួយចំនួនមិនបានបំភ្លឺឡើយ ប៉ុន្តែក្រុមហ៊ុនមិនបានធ្វើការកាត់កង ឬដកចំនួនម៉ោង ឬអំពូលដែលមិនបានបំភ្លឺនោះឡើយ ជាក់ស្តែងអំពូលដែលបានរាប់ជាក់ស្តែងមានចំនួន ១ ២២១ អំពូល ក្នុងនោះមានអំពូលមិនភ្លឺចំនួន ២៣ អំពូល និងអំពូលខ្សោយពន្លឺមានចំនួន ៦២ អំពូល។ ករណីលំអៀងអំពូលចំនួន៦៨ អំពូលពីការទូទាត់នេះ ដោយសារតែការជួសជុលផ្លូវជាតិលេខ៥ ខេត្តបានសំណូមពរឱ្យក្រុមហ៊ុនធ្វើការដកយកទុកសិន រង់ចាំពេលផ្លូវជួសជុលរួចក្រុមហ៊ុននឹងតម្លើងវិញ។[៤]

**៧. កង្វះខាតក្នុងការសហការជាមួយអ្នកបច្ចេកទេសមន្ទីរសាធារណការ និងដឹកជញ្ជូន**

កន្លងមកការអនុវត្តការងារសាងសង់/ជួសជុលបង្គោលភ្លើងបំភ្លឺសាធារណៈនៅខេត្តកំពង់ឆ្នាំង រដ្ឋបាលខេត្តមិនបានសហការជាមួយមន្ទីរសាធារណការ និងដឹកជញ្ជូន និងរដ្ឋបាលក្រុងកំពង់ឆ្នាំងឡើយ។ ម្យ៉ាងវិញទៀត មន្ទីរសាធារណការ និងដឹកជញ្ជូនដែលជាអ្នកបច្ចេកទេសក៏មិនបានចូលរួមជាមួយរដ្ឋបាលខេត្តដែរ។ បញ្ហាទាំងនេះបណ្តាលមកពីការអនុវត្តតាមទម្លាប់របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង។[៥]

---

[៣] កិច្ចសន្យាស្តីពីការផ្តល់សិទ្ធិវិនិយោគ ផ្គត់ផ្គង់ គ្រប់គ្រង និងប្រតិបត្តិការសេវាប្រព័ន្ធភ្លើងបំភ្លឺសាធារណៈ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ត្រង់ប្រការ៧ ចំណុច៧.២ ,៧.៣ និងប្រការ៦ ចំណុច៦.៤

[៤] កំណត់ហេតុស្តីពីការចុះពិនិត្យជាក់ស្តែងអំពូលភ្លើងបំភ្លឺសាធារណក្នុងខេត្តកំពង់ឆ្នាំង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣

[៥] ប្រកាសលេខ៤០៨ សក.ប្រក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកំពង់ឆ្នាំង ជំពូកទី២ ប្រការ ៤ ប្រការ៥ និងជំពូកទី៣ ប្រការ ៧ ចំណុចទី៨